ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :....................អ.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥

## ផ្ញើជូន

## លោកស្រី ខង់ មយូរ៉ា

លោកស្រីជាទីរាប់អាន,

ខ្ញុំ និងភរិយាខ្ញុំ ព្រមទាំងមន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ មានសេចក្តីក្រៀមក្រំយ៉ាងខ្លាំង ដោយបានទទួលដំណឹងថា លោក **ប៉ែន សមិទ្ធិ** និពន្ធនាយកកាសែតរស្មីកម្ពុជា គេហទំព័រ CEN និងជាប្រធានក្លឹបអ្នកកាសែតកម្ពុជា បានទទួលមរណភាពក្នុងជន្មាយុ ៥៧ ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់លោក **ប៉ែន សមិទ្ធិ** គឺជាការបាត់បង់ស្វាមីដ៏ឧត្តុងឧត្តមក៏ដូចជាការបាត់បង់បិតាប្រកបដោយព្រហ្មវិហារធម៌របស់បុត្រា បុត្រី លោកស្រី ។លោក **ប៉ែន សមិទ្ធិ** គឺជាអ្នកសារព័ត៌មានដែលមានកម្រិតវិជ្ជាជីវៈខ្ពស់ គោរពក្រមសីលធម៌បានល្អ។

ក្នុងឱកាសដ៏សែនខ្លោចផ្សាបំផុតនេះ ខ្ញុំ សូមសំដែងនូវការស្តាយស្រណោះអាឡោះអាល័យក្រៃលែង និងសូមចូលរួមរំលែកនូវមរណទុក្ខជាមួយលោកស្រី ព្រមទាំងបុត្រា បុត្រី បងប្អូន កូនចៅ ញាតិមិត្ត ជិតឆ្ងាយនៃសពលោក **ប៉ែន សមិទ្ធិ** ប្រកបដោយសមានទុក្ខនិងក្តីសង្វេគរកទីបំផុតគ្មាន ។

ខ្ញុំនិងភរិយា ព្រមទាំងមន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធលោក **ប៉ែន សមិទ្ធិ** បានឆាប់យោនយកកំណើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រីទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា ព្រមទាំងមន្ត្រីរាជការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ៕

**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

អៀង - មូលី